## ក្នុងច្បាប់ MINNESOTA ផ្នែក 144A.751

## អ្នកផ្តល់សេវាកម្មថែទាំអ្នកជម្ងឺចុងក្រោយទាំងអស់ មានសិទ្ធិ

អនុផ្នែកទី 1 ។ **សេចក្តីប្រកាសសិទ្ធិ ។** បុគ្គលដែលទទួលបានសេវាកម្មថែទាំលើកចុងក្រោយមានសិទ្ធិ៖

(1) ទទួលបានព័ត៌មានជាលាយលក្ខណ៍អក្សរអំពីសិទ្ធិនៃការទទួលបានសេវាកម្មថែទាំនៅផ្ទះជាមុន ឬក្នុងអំឡុងពេលធ្វើការវាយតម្លៃបឋម មុនពេលការចាប់ផ្តើមសេវាកម្មថែទាំនៅផ្ទះ រួមទាំងវិធានការដែលត្រូវធ្វើ ប្រសិនបើសិទ្ធិនោះត្រូវបានរំលោភបំពាន

(2) ទទួលបាន ការថែទាំ និងសេវាកម្មនានាអាស្រ័យលើ ស្ថានភាព គម្រោងការថែទាំផ្ទះ និងត្រូវទទួលយកលក្ខខណ្ឌស្តង់ដាការថែទាំ ផ្ទះ និងត្រូវស្ថិតក្នុងផ្នែកសកម្ម ក្នុងការបង្កើត និងផ្លាស់ប្តូរគម្រោង និងការវាយតម្លៃលើ ការថែទាំង និងសេវាកម្ម

(3) ត្រូវបានជូនដំណឹងជាមុនក្នុងការទទួល ការថែទាំ អំពី សេវាកម្មដែលនឹងត្រូវផ្តល់ឲ្យវិន័យចំពោះការថែទាំ ភាពញឹកញាប់នៃការចុះពិនិត្យដែលត្រូវបានផ្តល់ និងជម្រើសផ្សេងទៀតដែលមាន ហើយនឹងផលវិបាកនៃជម្រើសទាំងនេះ រួមទាំងផលវិបាកនៃការបដិសេធចំពោះសេវាកម្មទាំងនេះផងដែរ

(4) ត្រូវបានជូនដំណឹងជាមុន អំពីការផ្លាស់ប្តូរគម្រោងនៃសេវាកម្មថែទាំទីសំណាក់ និងចាត់វិធានការចំពោះការប្តូរណាមួយ

(5) បដិសេធចំពោះសេវាកម្ម ឬការប្រព្រឹត្តណាមួយ;

(6) ដឹងជាមុន ចំពោះការកម្រិតណាមួយទៅលើសេវាកម្ម ដែលផ្តល់ឲ្យដោយអ្នកផ្តល់ការថែទាំ និងមូលហេតុសម្រាប់ការផ្តល់សេវាកម្មក្នុងការបញ្ចប់សេវាកម្ម

(7) ដឹងជាមុនអំពីការទទួលបានសេវាកម្មថែទាំ ទោះបីជាសេវាថែទាំនោះ អាចត្រូវបានគ្របដណ្តប់ដោយការធានារ៉ាប់រងសុខភាព ជំនួយផ្នែកព្យាបាលការថែទាំសុខភាពសង្គម ឬកម្មវិធីគម្រោងសុខភាពផ្សេងទៀត ដែលបុគ្គលនោះបានចុះឈ្មោះទទួលយក

(8) តាមរយៈសំណើ ទទួលបានការវាយតម្លៃសំណងដោយសុចរិតពីអ្នកផ្តល់សេវា លើកលែងតែពីការទទួលយកពីគម្រោងថែទាំសុខភាពដែលបុគ្គលនោះបានចុះឈ្មោះ ។ ការវាយតម្លៃដោយសុចរិត ក៏ត្រូវ មាន តាមសំណើនៃបុគ្គលដែលមិនបានចុះឈ្មោះក្នុងក្រុមហ៊ុនធានារ៉ាប់រងសុខភាពដែរ ។ ព័ត៌មាននៃការបង់ប្រាក់នេះ មិនបង្កើតជាការវាយតម្លៃថ្លៃសេវាកម្មភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ឡើយ

(9) ដឹងថាអាចមានសេវាកម្មផ្សេងទៀត មាននៅក្នុង សមាគមន៍ រួមទាំងសេវាកម្មពេលស្លាប់ និងការផ្តល់ជូនការថែទាំទីសំណាក់ផ្សេងទៀត ហើយដឹងថាគួទទួលបានព័ត៌មានសេវាកម្មទាំងនោះនៅទីណា

(10) ជ្រើសយកអ្នកផ្តល់សេវាកម្ម ឬផ្លាស់ប្តូរអ្នកផ្តល់សេវាកម្មដែលមាន ដោយសេរី បន្ទាប់ពីចាប់ផ្តើមសេវាកម្ម ដែលស្ថិតក្នុងការកម្រិតនៃការធានារ៉ាប់រងសុខភាព ជំនួយផ្នែកព្យាបាល ការថែទាំសុខភាពសង្គម ឬកម្មវិធីសុខភាពផ្សេងទៀត

(11) ព័ត៌មានផ្ទាល់ខ្លួន ហិរញ្ញវត្ថុ និងការព្យាបាល ត្រូវរក្សាជាការសម្ងាត់ ហើយការបង្ហាញព័ត៌មានទាំងនេះត្រូវប្រាប់ដល់អ្នកផ្តល់សេវាកម្មអំពីគោលនយោបាយ'និងនីតិវិធី

(12) ត្រូវបានអនុញ្ញាតឲ្យចូលទៅកាន់ របាយការណ៍ និងព័ត៌មានសរសេរផ្សេងៗ ដកស្រង់ចេញពី របាយការណ៍ អនុឡោមតាមផ្នែកទី 144.335;

(13) ត្រូវបានបម្រើដោយបុគ្គលិកដែលទទួលបានការហ្វឹកហាត់ត្រឹមត្រូវ និងមានសមត្ថភាពក្នុងការបំពេញការងារ

(14) ត្រូវបានព្យាបាលដោយត្រឹមត្រូវ គួរសមនិងមានសិទ្ធិទទួលព្យាបាលត្រឹមត្រូវដោយគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ

(15) ការតវ៉ាដោយសម្តែងទាក់ទងនឹងការព្យាបាល ឬការថែទាំដែលត្រូវផ្តល់ឲ្យ ឬខកខានផ្តល់ឲ្យ ឬទាក់ទងនឹងខ្វះចន្លោះការគោរពគួរសម ចំពោះអ្នកជម្ងឺ ឬទ្រព្យសម្បត្តិរបស់អ្នកជម្ងឺ

(16) រួចផុតពីការរំលោភបំពានលើ រូបរាងកាយ ឬដោយពាក្យសម្តី

(17) ទទួលបានដំណឹងជាមុន ដោយមានហេតុផល អំពីការផ្លាស់ប្តូរសេវា ឬតម្លៃ យ៉ាងតិចចំនួនដប់ថ្ងៃ មុនការជូនដំណឹងបញ្ចប់សេវាកម្ម ដោយអ្នកផ្តល់សេវាលើកលែងតែក្នុងករណីដែល៖

(i) ការទទួលសេវាកម្ម ដែលផ្លាស់ប្តូរលក្ខខណ្ឌ ការងារ រវាងអ្នកផ្តល់ទីសំណាក់ និងបុគ្គលផ្តល់សេវាទីសំណាក់ ឬបង្កើតឲ្យមានការរំលោភបំពាន ឬបរិយាកាសការងារគ្មានសុវត្ថិភាពចំពោះបុគ្គលដែលផ្តល់សេវាកម្មទីសំណាក់

(ii) ការសង្គ្រោះបន្ទាន់សម្រាប់ អ្នកផ្តល់សេវាថែទាំមិនផ្លូវការ ឬការផ្លាស់ប្តូរលក្ខខណ្ឌ ចាំបាច់ក្នុងលក្ខខណ្ឌនៃការទទួលដែលបានកើតមានក្នុងសេវាកម្មចាំបាច់ ដែលលើសពីកិច្ចព្រមព្រៀងផ្តល់សេវាបច្ចុប្បន្ន ហើយដែលមិនអាចផ្តល់លក្ខខណ្ឌសុវត្ថិភាព ឬ

(iii) អ្នកទទួលមិនត្រូវបានបញ្ជាក់   ថាជាអ្នកជម្ងឺទៀតទេ

(18) ជាអ្នកសម្របសម្រួលការផ្ទេរ នៅពេលមានការផ្លាស់ប្តូរអ្នកផ្តល់ សេវាកម្ម

(19) ដឹងពីរបៀបទាក់ទងបុគ្គលដែលពាក់ព័ន្ធជាមួយ អ្នកផ្តល់សេវាកម្មដែលទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហា និងឲ្យអ្នកផ្តល់សេវាកម្មធ្វើការស៊ើបអង្កេត និង ព្យាយាមដោះស្រាយបណ្តឹងតវ៉ា ឬការទាមទារផ្សេងៗ

(20) ស្គាល់ឈ្មោះនិងអាសយដ្ឋានភ្នាក់ងារនៃរដ្ឋ ឬស្រុក ទាក់ទងដើម្បីសុំព័ត៌មានបន្ថែមឬជំនួយការ

(21) អះអាងអំពីសិទ្ធិទាំងនោះដោយផ្ទាល់ខ្លួន ឬដោយក្រុមគ្រួសារអ្នកជម្ងឺនៅពេលដែលអ្នកជម្ងឺត្រូវបានវាយតម្លៃថា   អសមត្ថភាព គ្មានប្រតិកម្មតបវិញ និង

(22) មានការឈឺចាប់ និងរោគសញ្ញា ដែលបានគ្រប់គ្រងលើកម្រិតសុខស្រួលដែលចង់បានរបស់អ្នកជម្ងឺ។

ប្រសិនបើអ្នកផ្តល់ការថែទាំចុងក្រោយបំពេញការងាក្នុងបរិវេណនៃទីសំណាក់ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ   ចំពោះ អ្នកជម្ងឺម្នាក់ៗ ត្រូវរួមមានចំនួន និងគុណភាពបុគ្គលិករួមទាំបុគ្គលិក និងបុគ្គលិកស្មគ្រចិត្តដែលធ្វើការឲ្យអ្នកផ្តល់សេវា ដើម្បីឲ្យអនុវត្ត តាមលក្ខខណ្ឌតម្រូវច្បាប់នៃរដ្ឋ MN ផ្នែក 4664.0390  តាមវេណនីមួយៗនៅលំនៅស្ថានរបស់អ្នកជម្ងឺ ។

**ប្រសិនបើលោកអ្នកមានការតវ៉ាចំពោះភ្នាក់ងារ ឬបុគ្គលដែលផ្តល់សេវាស្នាក់នៅដល់លោកអ្នក លោកអ្នកអាចទូរស័ព្ទទៅ សរសេរលិខិតជាលាយលក្ខណ៍អក្សរ ឬ អញ្ជើញទៅកាន់ការិយាល័យទទួលបន្ទុកសម្រួលបណ្តឹងផ្នែកសុខាភិបាល MINNESOTA ។ លោកអ្នកក៏ត្រូវទាក់ទងទៅកាន់ការិយាល័យនៃមន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្តឹង ផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង ។**

**ការិយាល័យទទួលបន្ទុកសម្រួលបណ្តឹង ផ្នែកសុខាភិបាល**

(651) 201-4201

1-800-369-7994

ទូរសារ៖ (651) 281-9796

**អាសយដ្ឋានប៉ុស្តិ៍៖**

មន្ទីរសុខាភិបាល Minnesota

ការិយាល័យទទួលបន្ទុក សម្រួលបណ្តឹងផ្នែកសុខាភិបាល

ផ្ទះលេខ 85 កន្លែងទីប្រាំពីរភាគខាងកើត បន្ទប់លេខ 300

ប្រអប់សំបុត្រលេខ 64970

ផ្លូវ ផូល (Paul) មីនណេសូតា (Minnesota) 55164-0970

**មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្តឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង**

(651) 431-2555

1-800-657-3591

ទូរសារ៖ (651) 431-7452

**អាសយដ្ឋានប៉ុស្តិ៍៖**

មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្តឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

ប្រអប់សំបុត្រលេខ 64971

ផ្លូវ Paul MN 55164-0971

**នាមអ្នកទទួលអាជ្ញាប័ណ្ណ៖** ______________________________

**ទូរស័ព្ទ៖** ____________________ **សារអេឡិចត្រូនិក៖** ____________________

**អាសយដ្ឋាន៖** ______________________________

**នាម/ងារ របស់បុគ្គលដែលជាអ្នកត្រូវទាក់ទងដោយផ្ទាល់ពេលមានបញ្ហាឬមានការតវ៉ា៖**

______________________________

សម្រាប់ជាជាព័ត៍មានតែប៉ុណ្ណោះ ហើយមិនមែនជាការបង្គាប់ឲ្យធ្វើនៅក្នុងអត្ថបទសេចក្តីប្រកាសសិទ្ធិឯកត្តជន ស្តីពីការផ្តល់សេវាស្នាក់នៅឡើយ៖ ច្បាប់ MN, ផ្នែក 144A.751

អនុផ្នែក 2. **ការបកស្រាយនិងការអនុវត្ត សិទ្ធិ**

សិទ្ធិក្នុងផ្នែកនេះ ត្រូវបានបង្កើតឡើងដើម្បីជាប្រយោជន៍ដល់បុគ្គលដែលទទួលការថែទាំចុងក្រោយនៃជីវិត ។ អ្នកផ្តល់សេវាស្នាក់នៅមិនស្នើ ឬតម្រូវឲ្យអតិថិជនប្រគល់សិទ្ធិទាំងនេះ ជាថ្នូរនៃលក្ខខណ្ឌក្នុងការទទួលយកសេវានោះឡើយ។ អ្នកថែទាំ ឬអ្នកមើលថែរក្សា ឬក្នុងករណីដែលគ្មានអ្នកថែទាំ ឬអ្នកមើលថែរក្សាទេ បុគ្គលដែលត្រូវចាត់តាំង អាចអនុវត្តសិទ្ធិទាំងនេះបាន ។ សេចក្តីប្រកាសសិទ្ធិនេះមិនជំនួសឬលុបចោលសិទ្ធិឬសេរីភាពផ្សេងទៀតដែល មានចំពោះបុគ្គលដែលទទួលបានការថែទាំចុងក្រោយ បុគ្គលដែលផ្តល់ការថែទាំចុងក្រោយ ឬអ្នកផ្តល់សេវាកម្មថែទាំអ្នកជម្ងឺចុងក្រោយដែលទទួលការអនុញ្ញាតតាមផ្នែកទី 144A.753 ។

អនុផ្នែក ។ 3. **សេចក្តីប្រកាស ។** សេចក្តីចម្លងសិទ្ធិទាំងនេះត្រូវផ្តល់ជូនបុគ្គលនោះ នៅពេលដែលចាប់ផ្តើមអនុវត្តការថែរក្សា ។ សេចក្តីចម្លើងត្រូវមានអាសយដ្ឋាន និងលេខទូរស័ព្ទការិយាល័យដោះស្រាយបណ្តឹងតវ៉ានិងការិយាល័យប្រជាពលរដ្ឋសម្រាប់សេវារយៈពេលវែង ហើយរៀបរាប់ដោយងសង្ខេបពីរបៀបដាក់ពាក្យបណ្តឹងជាមួយការិយាល័យទាំងនេះ ។ ព័ត៌មានអំពីការទាក់ទងនឹងការិយាល័យប្រជាពលរដ្ឋសម្រាប់ការថែទាំរយៈពេលវែងត្រូវបញ្ចូលទៅក្នុងការជូនដំណឹងផ្លាស់ប្តូរតម្លៃផ្តល់ឲ្យ និងក្នុងការជូនដំណឹងដែលអ្នកផ្តល់ការថែទាំចុងក្រោយចាប់ផ្តើមផ្ទេរ ឬបញ្ចប់សេវាកម្ម។